ព្រះរាជាណាចក្រកម្ពុជា
Kingdom of Cambodia
ជាតិ សាសនា ព្រះមហាក្សត្រ
Nation - Religion - King

ទីស្តីការ

ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍
Ministry of Posts and Telecommunications

រាជធានី. ភ្នំពេញ ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០០១

លេខ : ១៤១ បទ.ប្រក

# ប្រកាស

## ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ របស់មជ្ឈមណ្ឌលទូរស័ព្ទសាធារណៈ និងប័ណ្ណស័ព្ទ

## រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

-បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

-បានឃើញអនុក្រឹត្យលេខ ២០ អនក្រ/បក ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និង រដ្ឋលេខាធិការដ្ឋាន

-បានឃើញអនុក្រឹត្យលេខ ៦៦ អនក្រ/បក ចុះថ្ងៃទី ២២ ខែតុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

-យោងតាមស្មារតីអង្គប្រជុំថ្នាក់ដឹកនាំក្រសួង ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០១

-បានឃើញការងារចាំបាច់របស់ក្រសួង

## សម្រេច

**ប្រការ ១ :** មជ្ឈមណ្ឌលទូរស័ព្ទសាធារណៈ និង ប័ណ្ណស័ព្ទគឺជាអង្គភាព ស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់នាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស ។

**ប្រការ ២** : មជ្ឈមណ្ឌលទូរស័ព្ទសាធារណៈ និង ប័ណ្ណស័ព្ទ មានភារៈកិច្ច និងសិទ្ធអំណាចដូចតទៅ :

ក-អំពីភារៈកិច្ច

-ផ្តល់សេវាទូរស័ព្ទសាធារណៈដល់អតិថិជន

-ផ្តល់សេវា Prepaid Sevice ដល់អតិថិជន

-គ្រប់គ្រងប្រតិបត្តិថែទាំជួសជុលបណ្តាញនិងរាល់ឧបករណ៍បរិក្ខាទាំងពីរ ( Payphone & PIN Phone

-សរុបប្រៀបធៀបទិន្នន័យការលក់ប័ណ្ណស័ព្ទ និងក្រាហ្វិកប្រើប្រាស់

-រៀបចំផែនការលើកទិសដៅចំណូល និងចំណាយរយៈពេលវែង ខ្លីតាមមុខសញ្ញារបស់ខ្លួនដើម្បីបង្កើនប្រភពចំណូល និងអភិវឌ្ឍន៍បន្ថែមលើវិស័យនេះ ដោយសហការជាមួយអង្គភាពមានសមត្ថកិច្ច ។

-សរុប និងធ្វើរបាយការណ៍ជាប្រចាំស្តីពីស្ថានភាពបច្ចេកទេសអាជីវកម្មជូននាយកដ្ឋាន

ខ-សិទ្ធអំណាចរបស់មជ្ឈមណ្ឌលទូរស័ព្ទសាធារណៈ និង ប័ណ្ណស័ព្ទ

១-អនុវត្តន៍ការងារដែលបានការអនុញ្ញាតិពីនាយកដ្ឋាន

២-រួមសហការជាមួយការិយាល័យ និងមជ្ឈមណ្ឌលនានាក្នុងនាយកដ្ឋាន និងបណ្តាអង្គភាពមានសមត្ថកិច្ច

៣-ធ្វើសេវាកម្ម អាជីវកម្ម ទូរស័ព្ទសាធារណៈ និង ប័ណ្ណស័ព្ទ

៤-សហការជាមួយអាជ្ញាធរមូលដ្ឋាន ដើម្បីដោះស្រាយបញ្ហាទំនាស់បាតុភាពនានាដែលកើតមានឡើង

៥-កសាងបែបបទប្តឹងទៅអាជ្ញាធរមានសមត្ថកិច្ច ឬ តុលាការ នូវរាល់បញ្ហាដែលកើតមានឡើង

៦-សហការជាមួយកំលាំងមានសមត្ថកិច្ចក្នុងការចុះបង្រ្កាបលុបបំបាត់ចោលនៅអំពើខុសច្បាប់ដែលប៉ះពាល់ក្នុងវិស័យទូរស័ព្ទសាធារណៈ និង ប័ណ្ណស័ព្ទ

៧-លើកសំណើជ្រើសរើសប្រធានផ្នែក និងបុគ្គលិកមានស្នាដៃល្អជូននាយកដ្ឋាន ។

**ប្រការ ៣** : មជ្ឈមណ្ឌលទូរស័ព្ទសាធារណៈ និងប័ណ្ណស័ព្ទដឹកនាំដោយប្រធានមជ្ឈមណ្ឌល ១រូបនិងអនុប្រធានមួយចំនួនជាជំនួយការដែលត្រូវតែងតាំងដោយប្រកាសរបស់ក្រសួង ។

ផ្នែកនានាចំណុះមជ្ឈមណ្ឌលរួមមាន :

១-ផ្នែកអាជីវកម្ម និង ទីផ្សារ :

ផ្នែកអាជីវកម្ម និង ទីផ្សារ មានភារៈកិច្ច ធ្វើសេវាកម្មប័ណ្ណស័ព្ទ ត្រួតពិនិត្យប័ណ្ណស័ព្ទ សរុបទិន្នន័យ និង ផ្សព្វផ្សាយ ទីផ្សារអោយអតិថិជននិងប្រជាពលរដ្ឋយល់ច្បាស់អំពីការប្រើប្រាស់ទូរស័ព្ទសាធារណៈ និង ប័ណ្ណស័ព្ទ ។

ផ្នែកនេះមានក្រុមការងារចំនួន ៣ ក្រោមឱវាទ :

-ក្រុមសេវាប័ណ្ណទូរស័ព្ទ

-ក្រុមចល័ត និង ត្រួតពិនិត្យប័ណ្ណស័ព្ទ

-ក្រុមសរុបទិន្នន័យ

២-ផ្នែក Prepaid Service :

ផ្នែក Prepaid Service មានភារៈកិច្ចផ្តល់សេវា Prepaid និងស្តាបនាជួសជុលប្រព័ន្ធបរិធានទូរស័ព្ទ Prepaid

ផ្នែកនេះមានក្រុមការងារចំនួន ២ ក្រោមឱវាទ :

-ក្រុមប្រចាំការ

-ក្រុមស្តាបនាជួសជុល

៣-ផ្នែកប្រព័ន្ធគ្រប់គ្រងដំណើរការទូរស័ព្ទសាធារណៈ ( OPMS Operation Payphone Management System ) :

ផ្នែកប្រព័ន្ធគ្រប់គ្រងដំណើរការទូរស័ព្ទសាធារណៈ ( OPMS Operation Payphone Management System ) មានភារៈកិច្ចផ្តល់សេវាទូរស័ព្ទសាធារណៈស្តាបនាជួសជុលបរិធានទូរស័ព្ទសាធារណៈ ត្រួតពិនិត្យចរាចរសេវាទូរស័ព្ទប្រចាំថ្ងៃ ប្រចាំខែ និង សំរង់ទិន្នន័យរាល់ហេតុការណ៍ ដែលបណ្តាលអោយមានការរអាក់រអួលដោយបរិធានឬបច្ចេកទេស ។

ផ្នែកនេះមានក្រុមការងារចំនួន ២ ក្រោមឱវាទ :

-ក្រុមប្រចាំការ

-ក្រុមស្តាបនា និងជួសជុល

៤-ផ្នែកថែទាំជួសជុលបណ្តាញកាប្លិ៍ និង បរិធានទូរស័ព្ទសាធារណៈ :

ផ្នែកថែទាំជួសជុលបណ្តាញកាប្លិ៍ និង បរិធានទូរស័ព្ទសាធារណៈ មានភារៈកិច្ចជួសជុលថែទាំបណ្តាញត្រួតពិនិត្យរាល់បាតុភាពដែលកើតមានលើខ្សែបណ្តាញក្នុងករណីជនល្មើសលួចផ្តាក់ខ្សែនៅចន្លោះ MDS និងបរិធានទូរស័ព្ទ

ផ្នែកនេះមានក្រុមការងារចំនួន ២ ក្រោមឱវាទ :

-ក្រុមជួសជុលបណ្តាញកាប្លិ៍

-ក្រុមជួសជុលថែទាំបរិធានទូរស័ព្ទ

ផ្នែកនិមួយ ៗ ខាងលើ ដឹកនាំដោយប្រធានផ្នែក ១រូប និងអនុប្រធានមួយចំនួនជាចំនួយការ ។

រចនាសម្ព័ន្ធរបស់មជ្ឈមណ្ឌលទូរស័ព្ទសាធារណៈ និងប័ណ្ណស័ព្ទ ជាឧបសម្ព័ន្ធ នៃប្រកាសនេះ ។

ដើម្បីអោយមជ្ឈមណ្ឌលទូរស័ព្ទសាធារណៈ និងប័ណ្ណស័ព្ទដំណើរការល្អនោះគ្រប់ផ្នែកត្រូវសំរេចអោយប្រសើរនូវការងារដែលមជ្ឈមណ្ឌលប្រគល់អោយ និងត្រូវសាមគ្គីឯកភាពគ្នាលើរាល់សកម្មភាព ។

**ប្រការ ៤** : រាល់ប្រកាសទាំងឡាយណាដែលផ្ទុយពីខ្លឹមសារ នៃប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៥ :** ខុទ្ទកាល័យ , អធិការដ្ឋាន គ្រប់នាយកដ្ឋានក្រោមឱវាទក្រសួងត្រូវទទួលបន្ទុកអនុវត្តន៏តាមខ្លឹមសារ នៃប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

គាត ឈន់

**កន្លែងទទួល**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
  " ដើម្បីជូនជ្រាប "
- ដូចប្រការ ៥ " ដើម្បីអនុវត្តន៍ "
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**រចនាសម្ព័ន្ធមជ្ឈមណ្ឌលទូរស័ព្ទសាធារណៈ និងបណ្ណស័ព្ទ**

